# កិច្ចការធ្វើដោយដៃ នៃផែនការនៃសុភមង្គល

ធ្វើកិច្ចការធ្វើដោយដៃនេះដើម្បីជួយប្អូនបង្រៀនអំពីផែនការនៃសុភមង្គលរបស់ព្រះវរបិតាសួគ៌ ។
ប្អូនអាចអានអំពីផែនការនេះនៅក្នុង អាលម៉ា ១៨:៣៦, ៣៩ និង អាលម៉ា ២២:៨–១៦ ។

១. សូមកាត់បំណែកតាមចំណុចខ្សែបន្ទាត់ចុចៗខាងក្រោម ។ ចោះរន្ធមួយតាមរង្វង់ពណ៌សនីមួយៗ ។
២. ចងខ្សែតាមរន្ធដើម្បីភ្ជាប់បំណែកជាមួយពាក្យ និងរូបភាពដែលវាត្រូវជាមួយគ្នា ។ ចងខ្សែមួយទៀតតាមរន្ធនៅផ្នែកខាងលើ ។
៣. ចងខ្សែទាំងអស់ភ្ជាប់ទៅនឹងដំបង ។ បន្ទាប់មកព្យួរកិច្ចការធ្វើដោយដៃរបស់ប្អូន ។

**ការបង្កបង្កើត**
ព្រះបានបង្កើតស្ថានសួគ៌ និងផែនដី ហើយ
អ្វីៗទាំងអស់នៅក្នុងនោះ ។

**ការធ្លាក់**
អ័ដាម និងនាងអេវ៉ា បានជ្រើសរើស
បរិភោគផ្លែឈើដឹងខុសត្រូវ ដែលរឿងនេះ
អនុញ្ញាតឲ្យពួកគេមានគ្រួសារមួយ ។

**ជីវិតនៅលើផែនដី**
យើងកើតមកលើផែនដីដើម្បី
រៀនសូត្រ និងរីកចម្រើន ។

**ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ**
ព្រះយេស៊ូវគ្រីស្ទបានយាងមកផែនដី ជាផ្នែកមួយនៃដង្វាយធួនរបស់
ទ្រង់ ទ្រង់ទទួលរងនូវការឈឺចាប់ទាំងអស់របស់យើង ហើយបានបង់
ថ្លៃចំពោះអំពើបាបទាំងអស់របស់យើង ។ ទ្រង់បានសុគត ហើយបាន
រស់ឡើងវិញ ។ ដោយសារទ្រង់យើងអាចប្រែចិត្ត ហើយរស់ឡើងវិញ
ជាមួយនឹងព្រះវរបិតាសួគ៌ បន្ទាប់ពីយើងស្លាប់ទៅ ។







